## ការលុបចោលទោសប្រហារជីវិត៖ និន្នាការកំពុងមានការកើនឡើងនៅពាសពេញពិភពលោក

"គ្មានសិទ្ធិអ្វីដែលថ្លៃថ្លាជាងសិទ្ធិរស់រានមានជីវិតនោះទេ" នេះជាប្រសាសន៍រំលឹកឡើងវិញរបស់លោកស្រី ណាវី ពីឡៃ នាយិកាឧត្តមស្នងការនៅឯកិច្ចប្រជុំកំរិតខ្ពស់ស្តីពីទោសប្រហារជីវិត នៅញូវយ៉ក កាលពីខែកក្កដាកន្លងមក។

លោកស្រីបានធ្វើការកត់សំគាល់ពីការកើនចំនួនយ៉ាងធំធេង នៃរដ្ឋសមាជិករបស់សហប្រជាជាតិ ដែលបានទទួលស្គាល់ថា ទោសប្រហារជីវិត ធ្វើឲ្យខូចខាតដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងថាការលុបបំបាត់ទោសនេះ ឬយ៉ាងហោចណាស់ ផ្អាកការអនុវត្តសិន ក៏ជាកាយវិការចូលរួមក្នុងការលើកកំពស់ និងការវិវត្តន៍ជាលំដាប់ដល់សិទ្ធិមនុស្សដែរ។

ទោសប្រហារជីវិតគឺជាទម្រង់ចុងក្រោយគេនៃការដាក់ទណ្ឌកម្ម គឺតាមរយៈការដកហូតជីវិតរបស់បុគ្គលម្នាក់ដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ។ ទីណានៅតែមានទោសប្រហារជីវិត លក្ខខណ្ឌចំពោះអ្នកទាំងឡាយណាដែលរង់ចាំទោសប្រហារជីវិត គឺជាក្តីវន្ទត់ជានិច្ច ដែលជាការនាំឲ្យមានការឈឺចាប់កាន់តែធ្ងន់ធ្ងរ។

ថ្ងៃនេះ ទី១០ តុលា គឺជាទិវាសម្ព័ន្ធពិភពលោកប្រឆាំងនឹងទោសប្រហារជីវិត និងអ្នកមាននិន្នាការលុបបំបាត់ទោសនេះ ប្រារព្ធខួបលើកទី១០ នៃទិវាពិភពលោកប្រឆាំងនឹងទោសប្រហារជីវិត គឺជាគាំទ្រគំនិតផ្តួចផ្តើមជាសកលមួយ ដែលមានការគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។

នៅកម្ពុជា ទាំងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ទាំងការិយាល័យសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម សូមស្វាគមន៍រាជរដ្ឋាភិបាលកម្ពុជា ចំពោះជំហរដដែលៗពីការប្រឆាំងនឹងការអនុវត្តទោសប្រហារជីវិត។

កម្ពុជាបានស្ថិតនៅជួរមុខគេក្នុងការលុបបំបាត់ទោសប្រហារជីវិតនៅអាស៊ី ជាពិសេសក្នុងចំណោមបណ្តាប្រទេសអាស៊ាន កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសពីរ ដែលបានលុបបំបាត់ចោលទោសប្រហារជីវិតនៅក្នុងតំបន់ (ប្រទេសមួយទៀតនោះ គឺប្រទេសហ្វីលីពីន) និងជាប្រទេសដែលការលុបបំបាត់ទោសប្រហារជីវិតមានរយៈពេលបន្តយូរជាងគេ ដែលបានហាមឃាត់មិនឲ្យមានទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋទាំងអស់ តាំងពីឆ្នាំ១៩៨៩។ ស្ថានភាពនេះបានក្លាយជាការការពារតាមរដ្ឋធម្មនុញ្ញ នៅឆ្នាំ១៩៩៣ តាមរយៈមាត្រា៣២ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា ដែលបានលុបចោលទោសប្រហារជីវិតយ៉ាងដាក់ច្បាស់។

ក្នុងបណ្តាឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានគូសបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់ខ្លួន ដល់ការលុបបំបាត់ទោសប្រហារជីវិត ដោយបានបោះឆ្នោតគាំទ្រជាបន្តបន្ទាប់លើសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការផ្អាកការអនុវត្តទោសប្រហារជីវិតក្នុងឆ្នាំ២០០៧ ឆ្នាំ២០០៨ និងឆ្នាំ២០១០។ សេចក្តីសំរេចទាំងនេះក៏បានអំពាវនាវផងដែរ ឲ្យធ្វើការរឹតត្បិតលើចំនួននៃបទល្មើសដែលត្រូវទទួលទោសប្រហារ ជីវិត គោរពបទដ្ឋានអន្តរជាតិដែលចែងពីកិច្ចការពារដែលធានាបាននូវការការពារ ចំពោះអ្នកទាំងឡាយណាដែលប្រឈមមុខនឹងទោសប្រហារជីវិត និងការប្តេជ្ញាចិត្តមិនយកមកប្រើវិញនូវទោសប្រហារជីវិត នៅពេលដែលទោសនេះត្រូវបានលុបចោលហើយនោះ។ ក្នុងខែធ្នូ ឆ្នាំ២០១២នេះ មហាសន្និបាតអង្គការសហប្រជាជាតិ នឹងបោះឆ្នោតម្តងទៀតលើសេចក្តីសំរេចចិត្តលើកទី៤របស់ខ្លួន ស្តីពីការផ្អាកការអនុវត្តទោសប្រហារជីវិត។

ការលប់បំបាត់ទោសប្រហារជីវិតរបស់កម្ពុជា គឺជាប្រការគួរឲ្យកោតសរសើរទោះបីជាឃើញឧក្រិដ្ឋកម្មសាហាវឃោរឃៅ ដោយផ្ទាល់ភ្នែកនៅក្នុងប្រទេសនេះ ក្នុងកំឡុងពេលខ្មែរក្រហមក៏ដោយ។ ការផ្តន្ទាទោសដោយតុលាការកម្ពុជា លើលោកកាំង ហ្គេចអ៊ាវ ឲ្យជាប់ពន្ធនាគារអស់មួយជីវិតសំរាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ បានពង្រឹងសារដែលកម្ពុជាបានបោះបង់ឈប់អនុវត្តទោសប្រហារជីវិតទាំងក្នុងទ្រឹស្តីនិងការអនុវត្តជាក់ស្តែង។

ភាគច្រើនបំផុតនៃបណ្តាប្រទេសនៅក្នុងពិភពលោកនេះ ដែលបានលប់បំបាត់ទោសប្រហារជីវិត បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ ដែលមានគោលដៅបញ្ចប់ទោសប្រហារជីវិត បញ្ជូនសញ្ញាដ៏ច្បាស់លាស់មួយទៅកាន់សហគមន៍អន្តរជាតិ លើបញ្ហាសិទ្ធិមនុស្សដ៏សំខាន់មួយនេះ។

ដូច្នេះ នេះមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលពេកទេដែលរដ្ឋសមាជិកជាច្រើនរបស់សហប្រជាជាតិ បានផ្តល់អនុសាសន៍ឲ្យកម្ពុជាផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ ក្នុងកំឡុងពេលក្រុមប្រឹក្សាសិទ្ធិមនុស្សពិនិត្យលើរបាយការណ៍ជាសកលតាមកាលកំណត់របស់កម្ពុជា (UPR) កាលពីឆ្នាំ២០០៩-គឺជាអនុសាសន៍មួយដែលកម្ពុជាបានទទួលយក ថាជាការបង្ហាញជំហររបស់ព្រះរាជាណាចក្រនេះម្តងទៀតចំពោះទោសប្រហារជីវិត។

"សិទ្ធិរស់រានមានជីវិតគឺជាសិទ្ធិជាមូលដ្ឋានបំផុតនៃសិទ្ធិមនុស្សទាំងអស់" នេះគឺជាចំណាប់អារម្មណ៍របស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឯកិច្ចប្រជុំកាលពីខែកក្កដា នៅប៉ូរីញូយក។ ដោយលោកបានលើកទឹកចិត្តឲ្យរដ្ឋសមាជិកទាំងអស់ អនុវត្តតាមនិន្នាការកំពុងតែកើនឡើងនៅពេសពេញពិភពលោក សំដៅលប់បំបាត់ទោសប្រហារជីវិត។

លោកបានបន្តថា "សិទ្ធិនេះស្ថិតនៅចំក្រអៅបេះដូងនៃសិទ្ធិមនុស្សអន្តរជាតិ"។ "ការដកហូតអាយុជីវិត គឺវាដាច់ខាតពេក ហើយមិនអាចត្រឡប់ក្រោយវិញបាននោះទេ សំរាប់មនុស្សម្នាក់ ដាក់ទោសនេះទៅលើមនុស្សម្នាក់ទៀត ទោះបីជានៅពេលមានការគាំទ្រដោយដំណើរការតាមផ្លូវច្បាប់ក៏ដោយ។"

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញរួចហើយពីភាពជាអ្នកដឹកនាំដ៏មហិមា តាមរយៈការក្លាយជាសមាជិកអាស៊ានដំបូងគេ ផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។ នៅក្នុងឆ្នាំដ៏សំខាន់នេះ ដែលកម្ពុជាធ្វើជាប្រធានអាស៊ាន រាជរដ្ឋាភិបាលកម្ពុជាអាចបង្ហាញពីភាពជាអ្នកដឹកនាំដូចគ្នាចំពោះបញ្ហានៃទោសប្រហារជីវិត ដោយក្លាយជារដ្ឋសមាជិកអាស៊ានទី២ បន្ទាប់ពីប្រទេសហ្វីលីពីន ជារដ្ឋភាគីនៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

លោកជេមស៍ ហ៊ីណឺន តំណាងស្តីទីនៃOHCHR<br>
លោកអូលីវៀ ឡឺមេត នាយកប្រចាំប្រទេសនៃUNODC